ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២១ លេខ៩២ ត្រីមាសទី០៤ ឆ្នាំ២០២១

# រាជកិច្ច

ផ្សាយចេញពី

ទីស្ដីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្ដីសម្រេច បទបញ្ជា សារាចរ ប្រកាស

# ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ៣០-១២-២០២១ | -ព្រះរាជក្រឹត្យ នស/រកត/១២២១/៨៩២ ស្ដីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ត្រី ដល់លោកវរសេនីយ៍ឯក **ឡឿន ដារ៉ា** នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ | ១១៣៦៥ |
| ៣០-១២-២០២១ | -ព្រះរាជក្រឹត្យ នស/រកត/១២២១/៨៩៣ ស្ដីពី ការតែងតាំង និងផ្ដល់ឋានៈ សមាជិក ទីប្រឹក្សា និងជំនួយការ អមអនុប្រធាន និងសមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (កបស) ចំនួន ១៦ រូប | ១១៣៦៦ |


## II~រាជរដ្ឋាភិបាល

### អនុក្រឹត្យ


| | | |
|---|---|---|
| ៣០-១២-២០២១ | -អនុក្រឹត្យលេខ ២៧៨ អនក្រ.បក ស្ដីពី រូបសញ្ញា និងត្រារបស់ស្ថាប័នប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម | ១១៣៦៩ |
| ៣០-១២-២០២១ | -អនុក្រឹត្យលេខ ២៧៩ អនក្រ.បក ស្ដីពី ការកែសម្រួលផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ស្ថិតក្នុងរាជធានីភ្នំពេញ | ១១៣៧៦ |


## III~ការងារបណ្ដាក្រសួង

### ១~ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


| | | |
|---|---|---|
| ១៥-១២-២០២១ | -ប្រកាសលេខ ៨៤៨ សហវ.ប្រក ស្ដីពី ការតែងតាំងរជ្ជទេយ្យករចំណូល និងរជ្ជទេយ្យករចំណូលរង នៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខេត្តព្រះសីហនុ | ១១៣៨០ |
| ២០-១២-២០២១ | -ប្រកាសអន្តរក្រសួងលេខ ៨៦៣ សហវ.ប្រក ស្ដីពី ការកែសម្រួលអត្រាបែងចែកចំណូលពីសេវាសាធារណៈដែលប្រមូលបានដោយក្រសួងសាធារណការ និងដឹកជញ្ជូន | ១១៣៨២ |


### ២~ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍


| | | |
|---|---|---|
| ២-៧-២០២១ | -ប្រកាសលេខ ២២០ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អេស៊ា សាន់វ៉ាយ បង្កើតរោងចក្រ ផលិតស្រាបៀរ និងភេសជ្ជៈ | ១១៣៨៦ |
| ៦-៧-២០២១ | -ប្រកាសលេខ ២២២ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន កៃ យ៉ាង ស៊ុន ស៊ូ មេធៀរៀល ឯ.ក បង្កើតរោងចក្រ ផលិត និងបោះពុម្ព (លើគ្រឿងបន្សំស្បែកជើង និងគ្រឿងបន្សំសម្លៀកបំពាក់ | ១១៣៨៩ |
| ៦-៧-២០២១ | -ប្រកាសលេខ ២២៧ ឧវបន.កឧ.ប្រក ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ឃីងម៉េកឃើ (ខេមបូឌា) ហ្វូតវែរ បង្កើតរោងចក្រ ផលិតស្បែកជើង | ១១៣៩២ |

## ៣~ទីស្តីការរដ្ឋមន្ត្រីក្រសួងរ៉ែ និង ថាមពល


១៨-១-២០២១ -ប្រកាសលេខ ០០៥៤ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈលេខ ០០៥៤ រថ.អប្រក.លអ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០២១ ១១៣៩៥

១៨-១-២០២១ -ប្រកាសលេខ ០០៥៥ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០០៥៥ រថ.អប្រក.លអ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០២១ ១១៣៩៩

១៨-១-២០២១ -ប្រកាសលេខ ០០៥៦ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០០៥៦ រថ.អប្រក.លអ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០២១ ១១៤០៣

១៨-១-២០២១ -ប្រកាសលេខ ០០៥៧ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០០៥៧ រថ.អប្រក.លអ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០២១ ១១៤០៧

១៨-១-២០២១ -ប្រកាសលេខ ០០៥៨ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០០៥៨ រថ.អប្រក.លអ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០២១ ១១៤១១

១៨-១-២០២១ -ប្រកាសលេខ ០០៥៩ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០០៥៩ រថ.អប្រក.លអ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០២១ ១១៤១៥

១៨-១-២០២១ -ប្រកាសលេខ ០០៦០ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០០៦០ រថ.អប្រក.លអ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០២១ ១១៤១៩

១៨-១-២០២១ -ប្រកាសលេខ ០០៦១ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០០៦១ រថ.អប្រក.លអ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០២១ ១១៤២៣

១៨-១-២០២១ -ប្រកាសលេខ ០០៦២ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០០៦២ រថ.អប្រក.លអ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០២១ ១១៤២៧

១៨-១-២០២១ -ប្រកាសលេខ ០០៦៣ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០០៦៣ រថ.អប្រក.លអ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០២១ ១១៤៣១

១៨-១-២០២១ -ប្រកាសលេខ ០០៦៤ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០០៦៤ រថ.អប្រក.លអ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០២១ ១១៤៣៥

១៨-១-២០២១ -ប្រកាសលេខ ០០៦៥ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០០៦៥ រថ.អប្រក.លអ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០២១ ១១៤៣៩

១៨-១-២០២១ -ប្រកាសលេខ ០០៦៦ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០០៦៦ រថ.អប្រក.លអ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០២១ ១១៤៤៣

២-៨-២០២១ -ប្រកាសលេខ ០៧៨៧ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៧៨៧ រថ.អប្រក.លអ ចុះថ្ងៃទី ២ ខែ សីហា ឆ្នាំ ២០២១ ១១៤៤៧


## ៤~ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ


៥-៧-២០២១ -ប្រកាសលេខ ២៣២ ប្រក.កសក ស្តីពី បែបបទនៃការពិន័យអន្តរការណ៍ និងតម្លៃទីផ្សារពូជដំណាំជាមូលដ្ឋានសម្រាប់អនុវត្តការពិន័យអន្តរការណ៍ ១១៤៥១

# ព្រះរាជក្រឹត្យ

នស/រកត/១២២១/៩៧៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១**: តម្លើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ត្រី** ដល់លោកវរសេនីយ៍ឯក **ឡឿន ដារ៉ា** អត្តលេខ ៧៨២៧៦ នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២**: សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

នរោត្តម សីហមុនី

ពរស. ៥២១២. ៩១៣

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០២១*

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/១២២១/៨៩៣

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២០២/៣៥៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០២ ស្តីពីការបង្កើតឧត្តម-ក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៨/១៣៣៣ ចុះថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៨ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/១១១៣/១១៩០ ចុះថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/០៨០៧/៣៩៣ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/១២០២/៣៥៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០២ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រី ដែលមានឋានៈស្មើ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** តែងតាំង និងផ្តល់ឋានៈ សមាជិក ទីប្រឹក្សា និងជំនួយការ អមអនុប្រធាន និងសមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (**កបស**) ÷

១. ឯកឧត្តម **ផាន អូន** ជាសមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

២. ឯកឧត្តម **អៀប វ៉ាន់នី** ជាទីប្រឹក្សាឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

៣. ឯកឧត្តម **ហួត វឌ្ឍនា** ជាទីប្រឹក្សាឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

៤. លោកជំទាវ **ត្រុយ ណារិន** ជាទីប្រឹក្សាឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន

៥. លោកជំទាវ **ឈុន ដាលីន** ជាទីប្រឹក្សាឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន

៦. ឯកឧត្តម **ហ៊ាន សំបឿន** ជាទីប្រឹក្សាឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន

៧. ឯកឧត្តម **ហ៊ុល បុណ្ណារ័ត្ន** ជាជំនួយការឯកឧត្តម វង្សី វិស្សុត អនុប្រធាន **កបស**
មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន

៨. ឯកឧត្តម **ខឹម តុលា** ជាជំនួយការឯកឧត្តមបណ្ឌិតសភាចារ្យ ជួ វិជិត្ត អនុប្រធាន **កបស**
មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន

៩. ឯកឧត្តម **រៀម រដ្ឋា** ជាជំនួយការឯកឧត្តមបណ្ឌិតសភាចារ្យ ជួ វិជិត្ត អនុប្រធាន **កបស**
មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន

១០. ឯកឧត្តម **ប៊ុន ជីវ** ជាជំនួយការឯកឧត្តមបណ្ឌិតសភាចារ្យ ជួ វិជិត្ត អនុប្រធាន **កបស**
មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន

១១. ឯកឧត្តម **យូ ទី** ជាជំនួយការឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប អនុប្រធាន
ប្រចាំការ **កបស** មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន

១២. ឯកឧត្តម **វង្ស សាវ៉ាន់** ជាជំនួយការឯកឧត្តម ជាន់ ផល្លា សមាជិក **កបស**
មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន

១៣. ឯកឧត្តម **សួន សុផល** ជាជំនួយការឯកឧត្តម កាន ច័ន្ទមេត្តា សមាជិក **កបស**
មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន

១៤. ឯកឧត្តម **ជា ឡាលីន** ជាជំនួយការឯកឧត្តម យក់ ប៊ុនណា សមាជិក **កបស**
មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

១៥. ឯកឧត្តម **ស៊ុយ ប៊ុនថាន** ជាជំនួយការឯកឧត្តម យក់ ប៊ុនណា សមាជិក **គបស** មានឋានៈស្មើ **អគ្គនាយក** ដោយមិនទទួលយកប្រាក់បំណាច់មុខងារ។

១៦. ឯកឧត្តម **ហ៊ូ គុណវុឌ្ឍន៍** ជាជំនួយការឯកឧត្តម ប៉ែន ធីរុង្គ សមាជិក **គបស** មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

នស.រកត១២២១.៩១៤

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០២១*

នរោត្តមសីហមុនី

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ឧបនាយករដ្ឋមន្ត្រីប្រចាំការ

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ២៣៨ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## រូបសញ្ញានិងត្រារបស់ស្ថាប័នប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤ និងមាត្រា៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦២០/០២១ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- បានឃើញអនុក្រឹត្យលេខ ១៤២ អនក្រ.បក ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ

**សម្រេច**

**មាត្រា១ .-**

ត្រូវបានបង្កើតរូបសញ្ញានិងត្រារបស់ស្ថាប័នប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម សម្រាប់ប្រើប្រាស់ក្នុងដំណើរការការងាររបស់ខ្លួន។

ស្ថាប័នប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មសរសេរអក្សរកាត់ថា ស.ប.ស.ហ. ក្រុមប្រឹក្សាភិបាលនៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា សរសេរអក្សរកាត់ថា ប.ស.ហ.ក. និង អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា សរសេរអក្សរកាត់ថា ស.ហ.ក.។

**មាត្រា២ .-**

រូបសញ្ញារបស់ស្ថាប័នប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម មានអត្ថន័យ និងទម្រង់ដូចតទៅ៖

១- អក្សរ «៛» តំណាងឱ្យហិរញ្ញវត្ថុ ពណ៌ទឹកមាសតំណាងឱ្យភាពសម្បូររុងរឿង

២- រូបនាគពីរព័ទ្ធជុំវិញអក្សរ «៛» មានអត្ថន័យដូចតទៅ៖

ក- នាគតំណាងឱ្យការថែរក្សា និងការការពារប្រព័ន្ធហិរញ្ញវត្ថុ

ខ- នាគព័ទ្ធតំណាងឱ្យវិធានការត្រួតពិនិត្យ បង្ការ ទប់ស្កាត់ បង្ក្រាប និងលុបបំបាត់ការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មបានតាមគ្រប់រូបភាព

គ- ពណ៌ខៀវចាស់តំណាងឱ្យស្វយ័តភាព សាមគ្គីភាព ភាតរភាព សុចរិតភាព ការសម្ងាត់វិជ្ជាជីវៈ និងជំនឿទុកចិត្ត។

៣- ផ្នែកខាងលើនាគមានអក្សរ "**ស្ថាប័នប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម**" និងផ្នែកខាងក្រោមមានអក្សរជាភាសាអង់គ្លេស "Anti-Money Laundering and Combating the Financing of Terrorism Authority"។

ក្រុមប្រឹក្សាភិបាលនៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា អាចប្រើប្រាស់រូបសញ្ញានេះទាំងមូល ឬដោយផ្នែកបាន។

រូបសញ្ញារបស់ស្ថាប័នប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម មាននៅក្នុងឧបសម្ព័ន្ធ១ នៃអនុក្រឹត្យនេះ។

**មាត្រា៣ .–**

រូបសញ្ញារបស់ស្ថាប័នប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ត្រូវបានប្រើប្រាស់ដូចខាងក្រោម៖

- ដាក់នៅកន្លែងធ្វើការរបស់ស្ថាប័នប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- ដាក់នៅលើក្បាលលិខិតផ្លូវការរបស់ក្រុមប្រឹក្សាភិបាលនៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
- ប្រើប្រាស់សម្រាប់ស្ថាប័នប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ក្នុងករណីផ្សេងៗទៀត។

**មាត្រា៤ .–**

ស្ថាប័នប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មមានត្រាមូលពីរគឺ ត្រាប្រើប្រាស់សម្រាប់ក្រុមប្រឹក្សាភិបាលនៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងត្រាប្រើប្រាស់សម្រាប់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា។

ត្រារបស់ក្រុមប្រឹក្សាភិបាលនៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា មានវ័ណ្ឌពីរជាន់រំលេចរូបនាគពីរព័ទ្ធជុំវិញអក្សរ «ៈ» នៅចំកណ្ដាល។ នៅខាងក្រោមរូបនាគពីរព័ទ្ធជុំវិញអក្សរ «ៈ» មានឆ្លាក់អក្សរ "**ស្ថាប័នប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម**"។ ផ្នែកខាងលើមានឆ្លាក់អក្សរ "**ព្រះរាជាណាចក្រកម្ពុជា**" ស្របតាមវ័ណ្ឌ និងផ្នែកខាងក្រោមមានឆ្លាក់អក្សរ "**ក្រុមប្រឹក្សាភិបាលនៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា**" ស្របតាមវ័ណ្ឌ។ ត្រារបស់ក្រុមប្រឹក្សាភិបាលនៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា មាននៅក្នុងឧបសម្ព័ន្ធ២ នៃអនុក្រឹត្យនេះ។

ត្រារបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា មានវ័ណ្ឌពីរជាន់រំលេចរូបនាគពីរព័ទ្ធជុំវិញអក្សរ «ៈ» នៅចំកណ្ដាល។ នៅខាងក្រោមរូបនាគពីរព័ទ្ធជុំវិញអក្សរ «ៈ» មានឆ្លាក់អក្សរ "**ស្ថាប័នប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម**"។ ផ្នែកខាងលើមានឆ្លាក់អក្សរ "**ព្រះរាជាណាចក្រកម្ពុជា**" ស្របតាមវ័ណ្ឌ និងផ្នែកខាងក្រោមមានឆ្លាក់អក្សរ "**អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា**" ស្របតាមវ័ណ្ឌ។ ត្រារបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា មាននៅក្នុងឧបសម្ព័ន្ធ៣នៃអនុក្រឹត្យនេះ។

**មាត្រា៥ .–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងប្រធានអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១១រោច ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

បានយកសេចក្ដីគោរពជម្រាបជូន **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**និងជាប្រធាន គ.ស.ហ.**

**សម្ដេចក្រឡាហោម ស ខេង**

**<u>កន្លែងទទួល៖</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធ១៖ រូបសញ្ញារបស់ស្ថាប័នប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម**

**នៃអនុក្រឹត្យលេខ**.២៧៨.អនក្រ.បក.**ចុះថ្ងៃទី**.៣០.**ខែ**....ធ្នូ......**ឆ្នាំ**.២០២១

**ឧបសម្ព័ន្ធ២៖ ត្រារបស់ក្រុមប្រឹក្សាភិបាលនៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា**

**នៃអនុក្រឹត្យលេខ ២៣៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០២១**

**ឧបសម្ព័ន្ធ៣៖ ត្រារបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា**

**នៃអនុក្រឹត្យលេខ**២៣៧ អនក្រ.បក**ចុះថ្ងៃទី**៣០**ខែ**ធ្នូ**ឆ្នាំ**២០២១

ព្រះរាជាណាចក្រកម្ពុជា

ស្ថាប័នប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ២៧៧៩ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការកែសម្រួលផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ស្ថិតក្នុងរាជធានីភ្នំពេញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការកំណត់ផ្ទៃបឹងតាមោក(បឹងកប់ស្រូវ) ទំហំ ៣.២៣៩,៧ ហិកតា ស្ថិតក្នុងរាជធានីភ្នំពេញ ជាសម្បត្តិសាធារណៈរបស់រដ្ឋ

## សម្រេច

**មាត្រា ១:** ត្រូវបានកាត់ផ្ទៃដីចំនួន ០៧ (ប្រាំពីរ) ទីតាំង សរុបទំហំ ២០៩.៥៣៦ ម² (ពីររយប្រាំបួនពាន់ ប្រាំរយសាមសិបប្រាំមួយ ម៉ែត្រក្រឡា) ស្ថិតនៅសង្កាត់ពញាពន់ និងសង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ដែលត្រូវបានកំណត់ក្នុងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការកំណត់ផ្ទៃបឹងតាមោក (បឹងកប់ស្រូវ)ទំហំ ៣.២៣៩,៧ ហិកតា ស្ថិតក្នុងរាជធានីភ្នំពេញ ជាសម្បត្តិសាធារណៈរបស់រដ្ឋ ដើម្បីធ្វើអនុបយោគពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ក្នុងនោះ÷

- **ទីតាំងទី១** ទំហំ ១៣១៧ ម² (មួយពាន់ បីរយដប់ប្រាំពីរម៉ែត្រក្រឡា) ស្ថិតនៅសង្កាត់ពញាពន់ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ (ដូចមានតារាងនិយាមកា ភ្ជាប់ជាឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យនេះ)
- **ទីតាំងទី២** ទំហំ ១៧.៩១៥ ម² (ដប់ប្រាំពីរពាន់ ប្រាំបួនរយដប់ប្រាំម៉ែត្រក្រឡា) ស្ថិតនៅសង្កាត់ពញាពន់ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ (ដូចមានតារាងនិយាមកា ភ្ជាប់ជាឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យនេះ)
- **ទីតាំងទី៣** ទំហំ ១៤.៣១៩ ម² (ដប់បួនពាន់ បីរយដប់ប្រាំបួនម៉ែត្រក្រឡា) ស្ថិតនៅសង្កាត់ពញាពន់ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ (ដូចមានតារាងនិយាមកា ភ្ជាប់ជាឧបសម្ព័ន្ធទី៣ នៃអនុក្រឹត្យនេះ)
- **ទីតាំងទី៤** ទំហំ ២៨.៦៩២ ម² (ម្ភៃប្រាំបីពាន់ ប្រាំមួយរយកៅសិបពីរម៉ែត្រក្រឡា) ស្ថិតនៅសង្កាត់ពញាពន់ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ (ដូចមានតារាងនិយាមកា ភ្ជាប់ជាឧបសម្ព័ន្ធទី៤ នៃអនុក្រឹត្យនេះ)។
- **ទីតាំងទី៥** ទំហំ ៨០០៦ ម² (ប្រាំបីពាន់ ប្រាំមួយម៉ែត្រក្រឡា) ស្ថិតនៅសង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ (ដូចមានតារាងនិយាមកា ភ្ជាប់ជាឧបសម្ព័ន្ធទី៥ នៃអនុក្រឹត្យនេះ)
- **ទីតាំងទី៦** ទំហំ ១៦.១៧៦ ម² (ដប់ប្រាំមួយពាន់ មួយរយចិតសិបប្រាំមួយម៉ែត្រក្រឡា) ស្ថិតនៅសង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ (ដូចមានតារាងនិយាមកា ភ្ជាប់ជាឧបសម្ព័ន្ធទី៦ នៃអនុក្រឹត្យនេះ)
- **ទីតាំងទី៧** ទំហំ ១២៣.១១១ ម² (មួយរយម្ភៃបីពាន់ មួយរយដប់មួយម៉ែត្រក្រឡា) ស្ថិតនៅសង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ (ដូចមានតារាងនិយាមកា ភ្ជាប់ជាឧបសម្ព័ន្ធទី៧ នៃអនុក្រឹត្យនេះ)។

**មាត្រា ២** : ត្រូវបានធ្វើប្រទានកម្មផ្ទៃដីចំនួន ០៧ (ប្រាំពីរ) ទីតាំង សរុបទំហំ ២០៩.៥៣៦ ម² (ពីររយប្រាំបួនពាន់ ប្រាំរយសាមសិបប្រាំមួយម៉ែត្រក្រឡា) ស្ថិតនៅសង្កាត់ពញាពន់ និងសង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ខាងលើ ជាកម្មសិទ្ធិជូនលោកស្រី ហ៊ុន សេងនី និងលោក ឡាញ់ ភារ៉ា ដោយពន្ធ និងអាករផ្សេងៗ ជាបន្ទុករបស់រដ្ឋ។

**មាត្រា ៣** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នពាក់ព័ន្ធ អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១១កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល៖***

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី*
*-ដូចមាត្រា៤*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

ឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យលេខ...២៧៥.......អនក្រ.បក ចុះថ្ងៃទី...៣០.......ខែ...[illegible].........ឆ្នាំ២០២១
ស្ដីពីការកែសម្រួលផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ស្ថិតក្នុងរាជធានីភ្នំពេញ

| ល.រ | អាប់ស៊ីស | អ័រដោនេ | ល.រ | អាប់ស៊ីស | អ័រដោនេ |
|---|---|---|---|---|---|
| ១ | 476592.270 | 1288052.717 | ៤ | 476622.874 | 1288013.886 |
| ២ | 476627.365 | 1288056.495 | ៥ | 476597.961 | 1288012.782 |
| ៣ | 476626.917 | 1288018.063 | | | |

ឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យលេខ...២៧៥.......អនក្រ.បក ចុះថ្ងៃទី...៣០.......ខែ...[illegible]...........ឆ្នាំ២០២១
ស្ដីពីការកែសម្រួលផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ស្ថិតក្នុងរាជធានីភ្នំពេញ

| ល.រ | អាប់ស៊ីស | អ័រដោនេ | ល.រ | អាប់ស៊ីស | អ័រដោនេ |
|---|---|---|---|---|---|
| ១ | 476649.595 | 1288076.192 | ៩ | 476810.543 | 1288078.685 |
| ២ | 476650.439 | 1288148.595 | ១០ | 476794.956 | 1288077.746 |
| ៣ | 476713.538 | 1288152.188 | ១១ | 476733.822 | 1288078.671 |
| ៤ | 476835.297 | 1288153.777 | ១២ | 476706.828 | 1288078.400 |
| ៥ | 476894.669 | 1288158.222 | ១៣ | 476696.687 | 1288074.205 |
| ៦ | 476889.548 | 1288129.717 | ១៤ | 476664.666 | 1288072.132 |
| ៧ | 476885.403 | 1288082.989 | ១៥ | 476653.549 | 1288072.165 |
| ៨ | 476872.040 | 1288082.135 | | | |

ឧបសម្ព័ន្ធទី៣ នៃអនុក្រឹត្យលេខ...២៧៥......អនក្រ.បក ចុះថ្ងៃទី...៣០.......ខែ...[illegible]..........ឆ្នាំ២០២១
ស្ដីពីការកែសម្រួលផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ស្ថិតក្នុងរាជធានីភ្នំពេញ

| ល.រ | អាប់ស៊ីស | អ័រដោនេ | ល.រ | អាប់ស៊ីស | អ័រដោនេ |
|---|---|---|---|---|---|
| ១ | 476644.875 | 1288014.862 | ១២ | 476871.785 | 1288074.192 |
| ២ | 476640.925 | 1288018.684 | ១៣ | 476868.400 | 1287968.564 |
| ៣ | 476641.460 | 1288064.571 | ១៤ | 476815.230 | 1287973.022 |
| ៤ | 476649.689 | 1288064.176 | ១៥ | 476814.805 | 1287973.162 |
| ៥ | 476664.913 | 1288064.131 | ១៦ | 476814.960 | 1288002.056 |
| ៦ | 476698.524 | 1288066.308 | ១៧ | 476814.905 | 1288009.362 |
| ៧ | 476708.455 | 1288070.416 | ១៨ | 476813.748 | 1288014.859 |
| ៨ | 476733.801 | 1288070.670 | ១៩ | 476809.557 | 1288018.825 |
| ៩ | 476795.137 | 1288069.743 | ២០ | 476804.915 | 1288020.732 |
| ១០ | 476811.013 | 1288070.698 | ២១ | 476800.050 | 1288021.197 |
| ១១ | 476859.578 | 1288073.491 | ២២ | 476791.689 | 1288021.371 |

ឧបសម្ព័ន្ធទី៤ នៃអនុក្រឹត្យលេខ....២៧៧៥......អនក្រ.បក ចុះថ្ងៃទី...៣០.......ខែ....ធ្នូ.........ឆ្នាំ២០២១
ស្ដីពីការកែសម្រួលផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ស្ថិតក្នុងរាជធានីភ្នំពេញ

| ល.រ | អាប់ស៊ីស | អ័រដោនេ | ល.រ | អាប់ស៊ីស | អ័រដោនេ |
|---|---|---|---|---|---|
| ១ | 476519.440 | 1287913.516 | ១០ | 476587.065 | 1287854.266 |
| ២ | 476513.239 | 1287997.912 | ១១ | 476591.830 | 1287855.679 |
| ៣ | 476541.096 | 1287998.249 | ១២ | 476592.581 | 1287857.823 |
| ៤ | 476745.132 | 1288007.295 | ១៣ | 476597.313 | 1287876.098 |
| ៥ | 476751.587 | 1287919.114 | ១៤ | 476603.400 | 1287909.673 |
| ៦ | 476737.904 | 1287917.099 | ១៥ | 476584.538 | 1287912.281 |
| ៧ | 476742.931 | 1287876.293 | ១៦ | 476582.468 | 1287912.230 |
| ៨ | 476671.065 | 1287857.558 | ១៧ | 476550.751 | 1287906.264 |
| ៩ | 476586.902 | 1287848.489 | ១៨ | 476522.141 | 1287903.185 |

ឧបសម្ព័ន្ធទី៥ នៃអនុក្រឹត្យលេខ....២៧៧៥......អនក្រ.បក ចុះថ្ងៃទី...៣០.......ខែ....ធ្នូ.........ឆ្នាំ២០២១
ស្ដីពីការកែសម្រួលផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ស្ថិតក្នុងរាជធានីភ្នំពេញ

| ល.រ | អាប់ស៊ីស | អ័រដោនេ | ល.រ | អាប់ស៊ីស | អ័រដោនេ |
|---|---|---|---|---|---|
| ១ | 477154.233 | 1284623.657 | ៤ | 477205.017 | 1284693.060 |
| ២ | 477153.083 | 1284644.490 | ៥ | 477253.132 | 1284678.763 |
| ៣ | 477176.244 | 1284674.208 | ៦ | 477316.195 | 1284608.836 |

ឧបសម្ព័ន្ធទី៦ នៃអនុក្រឹត្យលេខ....២៧៧៥......អនក្រ.បក ចុះថ្ងៃទី...៣០.......ខែ....ធ្នូ.........ឆ្នាំ២០២១
ស្ដីពីការកែសម្រួលផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ស្ថិតក្នុងរាជធានីភ្នំពេញ

| ល.រ | អាប់ស៊ីស | អ័រដោនេ | ល.រ | អាប់ស៊ីស | អ័រដោនេ |
|---|---|---|---|---|---|
| ១ | 477161.007 | 1284500.926 | ៤ | 477331.317 | 1284567.309 |
| ២ | 477155.347 | 1284603.471 | ៥ | 477328.372 | 1284499.429 |
| ៣ | 477312.267 | 1284589.112 | | | |

ឧបសម្ព័ន្ធទី៧ នៃអនុក្រឹត្យលេខ....២៧៧៥......អនក្រ.បក ចុះថ្ងៃទី...៣០.......ខែ....ធ្នូ.........ឆ្នាំ២០២១
ស្ដីពីការកែសម្រួលផ្ទៃបឹងតាមោក (បឹងកប់ស្រូវ) ស្ថិតក្នុងរាជធានីភ្នំពេញ

| ល.រ | អាប់ស៊ីស | អ័រដោនេ | ល.រ | អាប់ស៊ីស | អ័រដោនេ |
|---|---|---|---|---|---|
| ១ | 477750.369 | 1284100.755 | ៦ | 477343.224 | 1283937.540 |
| ២ | 477704.987 | 1284073.630 | ៧ | 477388.267 | 1284495.714 |
| ៣ | 477635.890 | 1284034.713 | ៨ | 477389.023 | 1284513.149 |
| ៤ | 477558.872 | 1283993.425 | ៩ | 477751.878 | 1284110.800 |
| ៥ | 477514.946 | 1283970.265 | | | |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...សហវ....

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការកែសម្រួលអត្រាបែងចែកចំណូលពីសេវាសាធារណៈ ដែលប្រមូលបានដោយក្រសួងសាធារណការ និងដឹកជញ្ជូន

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៥/០០១ ចុះថ្ងៃទី៩ ខែមករា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៧/០០២ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា៨ មាត្រា៤០ មាត្រា៤១ មាត្រា៤៧ មាត្រា៤៨ មាត្រា៧៥ មាត្រា៧៧ មាត្រា៨២ និងមាត្រា៩០ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១១៥/០០១ ចុះថ្ងៃទី៩ ខែមករា ឆ្នាំ២០១៥



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្ដីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្ដីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ៧៣ អនក្រ.បក ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៩ ស្ដីពីការចុះបញ្ជីផ្ដល់បណ្ណសម្គាល់យានជំនិះ និងបំពាក់ផ្លាកលេខសម្គាល់យានជំនិះ
- បានឃើញប្រកាសអន្តរក្រសួងលេខ១៤៦០ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីការផ្ដល់សេវាសាធារណៈដោយក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញប្រកាសអន្តរក្រសួងលេខ១៤៦១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីការផ្ដល់ប្រាក់រង្វាន់លើការគ្រប់គ្រង និងការប្រមូលចំណូលពីកម្រៃសេវាសាធារណៈដោយក្រសួងសាធារណការ និងដឹកជញ្ជូន
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ប្រការ៣ នៃប្រកាសអន្តរក្រសួងលេខ១៤៦១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីការផ្ដល់ប្រាក់រង្វាន់លើការគ្រប់គ្រង និងការប្រមូលចំណូលពីកម្រៃសេវាសាធារណៈដោយក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវបានធ្វើការកែសម្រួល ដូចតទៅ ÷

**ប្រការ៣.- ថ្មី**

ចំណូលពីសេវាសាធារណៈដែលប្រមូលបានដោយក្រសួងសាធារណការ និងដឹកជញ្ជូន លើប្រភេទសេវាសាធារណៈ ដែលកំណត់ដោយប្រកាសអន្តរក្រសួងលេខ១៤៦០ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីការផ្ដល់សេវាសាធារណៈដោយក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវបានបែងចែកដូចខាងក្រោម ÷

| បរិយាយ | អត្រាបែងចែកធៀបនឹងចំណូលប្រមូលបាន | |
|---|---|---|
| | អត្រាចាស់ | អត្រាថ្មី |
| I. ចំណូលពីសេវាសាធារណៈដែលប្រមូលបានដោយអង្គភាពរដ្ឋបាលកណ្តាល | | |
| ១- ចំណូលពីសេវាសាធារណៈលើផ្នែកដឹកជញ្ជូនផ្លូវគោក និងផ្លូវទឹក | | |
| - បង់ចូលថវិកាជាតិ | ៩% | ៣៩% |
| - ប្រាក់រង្វាន់របស់ក្រសួងសាធារណការ និងដឹកជញ្ជូន | ៨៩% | ៥៩% |
| - ប្រាក់រង្វាន់សម្រាប់គាំទ្រមូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | ១% | ១% |
| - ប្រាក់រង្វាន់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១% | ១% |
| ២- ចំណូលពីសេវាសាធារណៈលើផ្នែកអាជ្ញាប័ណ្ណផ្លូវថ្នល់ | | |
| - បង់ចូលថវិកាជាតិ | ៦៩% | ៦៩% |
| - ប្រាក់រង្វាន់របស់ក្រសួងសាធារណការ និងដឹកជញ្ជូន | ២៩% | ២៩% |
| - ប្រាក់រង្វាន់សម្រាប់គាំទ្រមូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | ១% | ១% |
| - ប្រាក់រង្វាន់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១% | ១% |
| II. ចំណូលពីសេវាសាធារណៈដែលប្រមូលបានដោយមន្ទីរសាធារណការ និងដឹកជញ្ជូន រាជធានី ខេត្ត លើផ្នែកដឹកជញ្ជូនផ្លូវគោក និងផ្លូវទឹក | | |
| - បង់ចូលថវិកាជាតិ | ១០% | ៤០% |
| - ប្រាក់រង្វាន់របស់មន្ទីរសាធារណការ និងដឹកជញ្ជូន | ៨៩% | ៥៩% |
| - ប្រាក់រង្វាន់របស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១% | ១% |

ប្រការពីរ .–

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៣ .–**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២២ តទៅ។

ថ្ងៃចន្ទ ១រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**ស៊ុន ចាន់ថុល**

**កន្លែងទទួល ៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៥៤៥៥ សហវ.ប្រក

# ប្រកាស
## ស្ដីពី
## ការតែងតាំងរដ្ឋទេយ្យករចំណូល និងរដ្ឋទេយ្យករចំណូលរង នៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខេត្តព្រះសីហនុ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤១២ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/ រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២០/០៣៨ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្ដីពីការកែសម្រួលមាត្រា ៤៤ មាត្រា ៤៥ មាត្រា ៤៦ និងមាត្រា ៤៧ នៃអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្ដីពីការកែសម្រួល អនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពី បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១២១២ សហវ.ប្រក ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៨៩០ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការគ្រប់គ្រងរជ្ជទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**ប្រការ១.-**

ត្រូវបានតែងតាំងរជ្ជទេយ្យករចំណូល និងរជ្ជទេយ្យករចំណូលរង នៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខេត្តព្រះសីហនុ ដូចមានសមាសភាពខាងក្រោម÷

១. កញ្ញា **គុយ លីហួរ** អនុប្រធានការិយាល័យបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ ជារជ្ជទេយ្យករចំណូល

២. លោកស្រី **លឹម លីវត្ថា** អនុប្រធានការិយាល័យទ្រព្យសម្បត្តិរដ្ឋនិងចំណូល ជារជ្ជទេយ្យករចំណូលរង។ មិនមែនសារពើពន្ធ

**ប្រការ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣.-**

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកវិទ្យាស្ថាន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ១១កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- សាមីអង្គភាពថវិកា
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: [illegible]

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៤ ខែ[illegible] ឆ្នាំ២០២១

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងលិខិតលេខ២៣៣៨/១១ គ.វ.ក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១១ ស្តីពីការវិនិយោគលើគំរោងបង្កើតរោងចក្រផលិតស្រាបៀរ និងភេសជ្ជៈគ្រប់ប្រភេទ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២១ របស់ក្រុមហ៊ុន អេស៊ា សាន់រ៉ាយ

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន អេស៊ា សាន់រ៉ាយ (ASIA SUNRISE CO., LTD.) តំណាងដោយលោកស្រី **អ៊ិន ហ៊ុន** សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ 040025929(01) ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ បង្កើតរោងចក្រផលិតស្រាបៀរ និងភេសជ្ជៈ ដែលមានទីតាំងស្ថិតនៅភូមិបឹងកក់ ឃុំលង្វែក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង។

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
|---|---|
| ១- ស្រាបៀរ | ១១០៣ |
| ២- ភេសជ្ជៈ | ១១០៤ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ **"រោងចក្រផលិតស្រាបៀរ និងភេសជ្ជៈ អេស៊ា សាន់វ៉ាយ "**

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** ប្រកាសបង្កើតរោងចក្រលេខ១៣៥ ឧស.កឧ.ប្រក.០៣ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៥ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តកំពង់ឆ្នាំង និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះតាមមុខការ រៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ**
**បច្ចេកវិទ្យា និងនវានុវត្តន៍**
**រដ្ឋលេខាធិការ**

**មាន សុភា**

<u>ចម្លងជូន៖</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងបរិស្ថាន
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-រាជកិច្ច
-វិទ្យាស្ថានស្តង់ដារកម្ពុជា
-មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
-សាលាខេត្តកំពង់ឆ្នាំង
-មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តកំពង់ឆ្នាំង
-រដ្ឋបាលស្រុកកំពង់ត្រឡាច
-រដ្ឋបាលឃុំលង្វែក
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ...

ថ្ងៃ... ខែ... ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ២០២១

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងសំណើសុំប្រកាសបង្កើតរោងចក្រផលិតគ្រឿងបន្សំស្បែកជើង ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១ របស់ក្រុមហ៊ុន កៃ យ៉ាង ស៊ីន ស៊ូ មេធៀរៀល ឯ.ក

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន កៃ យ៉ាង ស៊ីន ស៊ូ មេធៀរៀល ឯ.ក **(KAI YANG XIN SHOES MATERIAL CO., LTD.)** តំណាងដោយលោក **WANG, GUANLONG** សញ្ជាតិចិន កាន់លិខិតឆ្លងដែនលេខ EE4221385 ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៨ បង្កើតរោងចក្រផលិត និងបោះពុម្ព(លើគ្រឿងបន្សំស្បែកជើង និងគ្រឿងបន្សំសម្លៀកបំពាក់) ដែលមានទីតាំងស្ថិតនៅភូមិអន្លង់ស ឃុំពងទឹក ស្រុកដំណាក់ចង្អើរ ខេត្តកែប។

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម** ISIC Rev.4 Code |
|---|---|
| ១- គ្រឿងបន្សំស្បែកជើង និងគ្រឿងបន្សំសម្លៀកបំពាក់(បោះពុម្ព) | ១៨១១ |
| ២- គ្រឿងបន្សំស្បែកជើង | ១៥២០ |
| ៣- គ្រឿងបន្សំសម្លៀកបំពាក់ | ១៤១០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំ ស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។
ស្លាកឈ្មោះរោងចក្រ៖ "រោងចក្រផលិត និងបោះពុម្ព(លើគ្រឿងបន្សំស្បែកជើង និងគ្រឿងបន្សំសម្លៀកបំពាក់) កៃ យ៉ាង ស៊ីន ស៊ូ មេជៀរៀល ឯ.ក"

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

២. លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៤.-**

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមសារាចរលេខ ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែ និងថាមពលដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះនូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. មិនអនុញ្ញាតឱ្យមានលំនៅដ្ឋានក្នុងបរិវេណស្ថានីយ

២. មិនអនុញ្ញាតឱ្យលក់ប្រេងច្រកប៊ីដុង និងចែកចាយក្នុងបរិវេណស្ថានីយ

៣. ពោងប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ១ម៉ែត្រ ពីគ្រឹះសំណង់អគារ

៤. ពោងសម្រាប់ដាក់ប្រេងឥន្ធនៈគ្រប់ប្រភេទនៅក្នុងស្ថានីយត្រូវកប់ក្រោមដី

៥. ត្រូវបំពាក់គន្លឹះអាសន្ននៅតាមទូចាក់ប្រេងឥន្ធនៈនីមួយៗ និងគន្លឹះអាសន្នរួម

៦. ទុយោទូចាក់ប្រេងឥន្ធនៈមិនត្រូវមានប្រវែងលើសពី ៦ម៉ែត្រ

៧. ត្រូវមានប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក

**ប្រការ៥.-**

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពល ក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ៦.-**

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

**ប្រការ៧.-**

ម្ចាស់ស្ថានីយត្រូវផ្តល់ឱ្យបានត្រឹមត្រូវនូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

**ប្រការ៨.-**

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធភាពខ្ពស់។

**ប្រការ៩.-**

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

**ប្រការ១០.-**

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាត នៃក្រសួងរ៉ែនិងថាមពលរយៈពេល១ (មួយ) ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

**ប្រការ១១.-**

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយលេខ ០០៦៦ រ៉ថ.ថប/អក.ណអ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ២០២១ របស់ក្រសួងរ៉ែ និងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១២.-.**

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈ ពេល១២ (ដប់ពីរ)ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬល្មើសផ្ទុនផ្ទួននឹងប្រការណាមួយខាងលើនោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ០០៦៦.[illegible] ចុះ [illegible] ថ្ងៃទី....១៨....ខែមករា..........ឆ្នាំ២០២១....នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

**ប្រការ១៣.-.**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយក នៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែ និងថាមពល ខេត្តត្បូងឃ្មុំ និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ.ចន្ទ...៦កើត...ខែ...មាឃ....ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨...ខែមករា...ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- សាលាខេត្តត្បូងឃ្មុំ
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងរ៉ែ និងថាមពល**
**Ministry of Mines and Energy**
លេខ: ០៧៨៧.រ៉ែ..អប្រក.ប្រក.

# ប្រកាស
## ស្តីពី
## លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ
## លេខ.០៧/៨៧.រ៉ែ.អប្រក.លអ ចុះថ្ងៃទី...០៤.....ខែ..សីហា....ឆ្នាំ២០២១

## រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែ និងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ ( ៥១ ) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ ( ៨៥៥ ) ២៣ ២១៩ ៥៧៤ ទូរសារ ( ៨៥៥ ) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០២១ របស់លោក **កាក់ គុណ**
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល។

## សម្រេច

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ មានស្លាកយីហោឈ្មោះ **LHR ផ្សារមេមត់** ស្ថិតនៅភូមិម៉ាស៊ីនទឹក ឃុំមេមត់ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ របស់លោក **កាក់ គុណ** (**ម្ចាស់ស្ថានីយ**)។

**ប្រការ២.-**

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

**ប្រការ៣.-**

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមប្រកាសលេខ០១៤១រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែ និងថាមពល ដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោម ក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

- លិខិតអនុញ្ញាតសាងសង់ពីអាជ្ញាធរដែនដី
- លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៤.-**

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមសារាចរលេខ០១៤០រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល ដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើ ឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះនូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. គួរពង្រីកក្បាលដីស្ថានីយឱ្យបានប្រវែងអប្បបរមា ២៥ម៉ែត្រ
២. មិនអនុញ្ញាតឱ្យបញ្ចូល និងលក់ចែកចាយប្រេងឥន្ធនៈតាមប៊ីដុងជ័រក្នុងបរិវេណស្ថានីយ
៣. ពោងប្រេងឥន្ធនៈមួយដាក់ប្រេងឥន្ធនៈបានតែមួយប្រភេទប៉ុណ្ណោះ
៤. ត្រូវមានរបាំងការពារការប៉ះទង្គិចបំពង់ខ្យល់ប្រេងឥន្ធនៈ

៥. ត្រូវមានកបំពង់ទទួលប្រេងឥន្ធនៈ
៦. ខឿនទូចាក់ប្រេងឥន្ធនៈត្រូវមានទំហំសមស្របតាមសារាចរ របស់ក្រសួងរ៉ែ និងថាមពល
៧. ទូចាក់ប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ៦ម៉ែត្រ ពី របងព្រំដីស្ថានីយ
៨. ទូចាក់ប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ៦ម៉ែត្រ ពី អគារការិយាល័យ
៩. ត្រូវបំពាក់គន្លឹះអាសន្នរួម និងគន្លឹះអាសន្ននៅតាមទូចាក់ប្រេងឥន្ធនៈនីមួយៗ
១០. ទុយោចាក់ប្រេងឥន្ធនៈមិនត្រូវមានប្រវែងលើសពី ៦ម៉ែត្រ
១១. ត្រូវមានគូសគំនូសសញ្ញាសម្រាប់ចំណតរថយន្តស៊ីទែនផ្ទេរប្រេងឥន្ធនៈ
១២. ត្រូវមានស្លាកសញ្ញាបម្រាមស្តីពីសុវត្ថិភាពឱ្យបានគ្រប់គ្រាន់
១៣. ត្រូវមានផ្ទាំងព័ត៌មានស្តីពីនីតិវិធីនៃការផ្ទេរប្រេងឥន្ធនៈ
១៤. ត្រូវមានប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក។

**ប្រការ៥.-**

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ៦.-**

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

**ប្រការ៧.-**

ម្ចាស់ស្ថានីយត្រូវផ្តល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

**ប្រការ៨.-**

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធភាពខ្ពស់។

**ប្រការ៩.-**

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន អំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

**ប្រការ១០.-**

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពលរយៈពេល ១ (មួយ) ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

**ប្រការ១១.-**

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយ លេខ០៧៨៧.រ.ធ.អ.ស.ក.ធអ.....ចុះថ្ងៃទី.....០៦..........ខែ..សីហា.......ឆ្នាំ២០២១...............របស់ក្រសួងរ៉ែ និងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១២.-**

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ)ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើ នោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ.០៧៨៧.រ.ធ.អ.ស.ក.ធអ ចុះថ្ងៃទី....០៦......ខែ..សីហា..........ឆ្នាំ២០២១...នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

**ប្រការ១៣.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែ និងថាមពលខេត្តត្បូងឃ្មុំ និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ.ច័ន្ទ.....៩រោច...ខែទុតិយាសាឍ ឆ្នាំឆ្លូវ...ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..១៦..ខែ.សីហា....ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តត្បូងឃ្មុំ
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ២៣២ ប្រក.កសក

# ប្រកាស

## ស្តីពី

## បែបបទនៃការពិន័យអន្តរការណ៍ និងតម្លៃទីផ្សារពូជដំណាំ ជាមូលដ្ឋានសម្រាប់អនុវត្តការពិន័យអន្តរការណ៍

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៥ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកៃលម្អដីកសិកម្មទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

១/៧

-បានឃើញអនុក្រឹត្យលេខ១៧៨ អនក្រ.បក ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២០ ស្តីពីឯកសណ្ឋាន និងសញ្ញាសម្គាល់របស់ភ្នាក់ងារអធិការកិច្ចពូជដំណាំ

-បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការសម្រួលមាត្រា២ មាត្រា២៥ មាត្រា២៦ និងមាត្រា៣៥ នៃអនុក្រឹត្យលេខ១១៨ អនក្រ.កប ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ និងមាត្រា២៧ថ្មី នៃអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧

-បានឃើញអនុក្រឹត្យលេខ១៦៣ អនក្រ.បក ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានពូជដំណាំចំណុះអគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញប្រកាសអន្តរក្រសួងលេខ១៧៥ កយ.កសក.ប្រក/១៧ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌

-យោងតាមតម្រូវការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់នូវបែបបទ នីតិវិធី និងសិទ្ធិពិន័យអន្តរការណ៍ ព្រមទាំងតម្លៃទីផ្សារពូជដំណាំជាមូលដ្ឋានសម្រាប់អនុវត្តការពិន័យអន្តរការណ៍ លើបទល្មើសអាជីវកម្មពូជដំណាំ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ។

**ប្រការ ២.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះការពិន័យអន្តរការណ៍លើបទល្មើសអាជីវកម្មពូជដំណាំស្របតាមមាត្រា៧៨ និងមាត្រា៧៩ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ។

## ជំពូកទី២
## សមត្ថកិច្ច និងសិទ្ធិអនុវត្តការពិន័យអន្តរការណ៍

**ប្រការ ៣.-**

ត្រូវបានផ្តល់សមត្ថកិច្ច និងសិទ្ធិពិន័យអន្តរកាណ៍លើបទល្មើសអាជីវកម្មពូជដំណាំ ដូចបានកំណត់ក្នុងមាត្រា៧៨ និងមាត្រា៧៩នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ ដល់ភ្នាក់ងារអធិការកិច្ចពូជដំណាំមាននីតិសម្បទាជានគរបាលយុត្តិធម៌ ដែលបម្រើការងារនៅនាយកដ្ឋានពូជដំណាំ របស់អគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត។

**ប្រការ ៤.-**

ភ្នាក់ងារអធិការកិច្ចពូជដំណាំ ដែលមាននីតិសម្បទាជានគរបាលយុត្តិធម៌ នាយកដ្ឋានពូជដំណាំរបស់អគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិអនុវត្តការពិន័យអន្តរការណ៍ លើដែនដីជាតិទូទាំងព្រះរាជាណាចក្រកម្ពុជា។

២/៧

ភ្នាក់ងារអធិការកិច្ចពូជដំណាំ ដែលមាននីតិសម្បទាជានគរបាលយុត្តិធម៌នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត មានសិទ្ធិអនុវត្តការពិន័យអន្តរការណ៍ នៅក្នុងដែនដីរាជធានី ខេត្តសាមី។

**ប្រការ ៥.–**

អគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមាននាយកដ្ឋានពូជដំណាំជាសេនាធិការ មានសិទ្ធិសម្រេចពិន័យអន្តរការណ៍លើគ្រប់បទល្មើស ដែលមានចែងក្នុងមាត្រា៧៨ និងមាត្រា៧៩ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ។

**ប្រការ ៦.–**

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត មានសិទ្ធិសម្រេចពិន័យអន្តរការណ៍លើគ្រប់បទល្មើស ដែលមានចែងក្នុងមាត្រា៧៨ និងមាត្រា៧៩ នៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ ដូចខាងក្រោម៖

១. មាត្រា៧៨ ចំណុចទី៣ គ្រែទី៥ ។

២. មាត្រា៧៩ ចំណុចទី១ ចំណុចទី២ ចំណុចទី៥ និងចំណុចទី៦។

ករណីដែលរកឃើញបទល្មើសផ្សេងពីបទល្មើសដូចបានកំណត់ក្នុងកថាខណ្ឌទី១ ខាងលើ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ត្រូវបញ្ជូនសំណុំរឿងបទល្មើស ដោយភ្ជាប់ជាមួយនូវកំណត់ហេតុត្រួតពិនិត្យ លិខិតសារភាពកំហុស និងយល់ព្រមបង់ប្រាក់ពិន័យអន្តរការណ៍ និងសំណុំ បែបបទពាក់ព័ន្ធ និងសំណាកវត្ថុតាង មកនាយកដ្ឋានពូជដំណាំនៃអគ្គនាយកដ្ឋានកសិកម្ម ដើម្បីសម្រេចលើការពិន័យអន្តរការណ៍ ស្របតាមបទប្បញ្ញត្តិ និងនីតិវិធីនៃច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ។

## ជំពូកទី៣
## បែបបទ និងនីតិវិធីពិន័យអន្តរការណ៍

**ប្រការ ៧.–**

នៅក្នុងប្រតិបត្តិការអធិការកិច្ចពូជដំណាំ ក្នុងករណីជួបប្រទះបទល្មើស ភ្នាក់ងារអធិការកិច្ចពូជដំណាំមានសមត្ថកិច្ចដឹកនាំបេសកកម្ម ត្រូវបំពេញកំណត់ហេតុត្រួតពិនិត្យ និងសំណុំបែបបទពាក់ព័ន្ធ ដោយត្រូវចង្អុលបង្ហាញនូវអង្គហេតុ អង្គច្បាប់ និងកំហុសដែលសាមីជនបានប្រព្រឹត្តល្មើសច្បាប់ ដើម្បីសាមីជននោះទទួលស្គាល់កំហុសរបស់ខ្លួន និងយល់ព្រមផ្តិតស្នាមម្រាមដៃលើកំណត់ហេតុត្រួតពិនិត្យ។

**ប្រការ ៨.–**

ភ្នាក់ងារអធិការកិច្ចពូជដំណាំមានសមត្ថកិច្ច មានសិទ្ធិចាត់វិធានការនៅនឹងកន្លែង ចំពោះករណីបទល្មើសដែលត្រូវពិន័យអន្តរការណ៍ ដោយត្រូវចុះក្នុងកំណត់ហេតុត្រួតពិនិត្យនូវវិធានការណាមួយ ក្នុងចំណោមវិធានការដូចខាងក្រោម៖

១. ការឃាត់ទុកវត្ថុតាង ជាបណ្តោះអាសន្ន។

២. ការផ្អាកជាបណ្តោះអាសន្ន ចំពោះសកម្មភាពល្មើសច្បាប់របស់គ្រឹះស្ថានអាជីវកម្មពូជដំណាំ មធ្យោបាយដឹកជញ្ជូន ឬផ្ទុកពូជដំណាំ និងទីតាំង ឬមធ្យោបាយផ្សេងទៀតដែលពាក់ព័ន្ធនឹងការប្រព្រឹត្តល្មើស។

៣. ការដកហូតជាបណ្តោះអាសន្ននូវវិញ្ញាបនបត្រ ឬលិខិតអនុញ្ញាតពាក់ព័ន្ធការធ្វើអាជីវកម្មពូជដំណាំ។

៤. ការដកយកគំរូសំណាកពូជដំណាំ។

៣/៧៥

៥. ការប្រគល់ ទទួល និងថែរក្សាវត្ថុតាង។

៦. វិធានការផ្សេងទៀត ស្របតាមបទប្បញ្ញត្តិជាធរមាន។

**ប្រការ ៩.-**

ភ្នាក់ងារអធិការកិច្ចពូជដំណាំមានសមត្ថកិច្ច ត្រូវចុះក្នុងកំណត់ហេតុត្រួតពិនិត្យនូវបញ្ជីវត្ថុតាងល្មើស ដែលឃាត់ទុក ឬចាប់យកបណ្ដោះអាសន្ន និងបញ្ជីគំរូសំណាកពូជដំណាំដែលបានដកយកសម្រាប់ធ្វើពិសោធន៍ គុណភាពពូជដំណាំ។

ក្នុងករណីវត្ថុតាងល្មើសត្រូវថែរក្សាទុកនៅកន្លែងកើតហេតុ ភ្នាក់ងារអធិការកិច្ចពូជដំណាំមានសមត្ថកិច្ច ត្រូវបិទស្លាកសម្គាល់លើវត្ថុតាង បំពេញកំណត់ហេតុប្រគល់ ទទួល និងថែរក្សាវត្ថុតាង ដើម្បី ប្រគល់ឱ្យរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយនៅមូលដ្ឋាន ឬទីកន្លែងកើតហេតុនោះ ថែរក្សាទុកជាបណ្ដោះអាសន្ន រហូតដល់ករណីបទល្មើសត្រូវបានដោះស្រាយរួចជាស្ថាពរ។

**ប្រការ ១០.-**

ភ្នាក់ងារអធិការកិច្ចពូជដំណាំមានសមត្ថកិច្ចដឹកនាំបេសកកម្ម ដែលមាននីតិសម្បទាជានគរបាលយុត្តិធម៌ អាចអនុវត្តការពិន័យអន្តរការណ៍បាន ក្នុងករណីជនល្មើសសារភាពកំហុសជាលាយលក្ខណ៍អក្សរ ដោយយល់ព្រម បង់ប្រាក់ពិន័យអន្តរការណ៍ ស្របតាមទោសប្បញ្ញត្តិនៃច្បាប់ស្ដីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ ពូជដំណាំ។

ជនប្រព្រឹត្តល្មើសអាចធ្វើលិខិតសារភាពកំហុស និងយល់ព្រមបង់ប្រាក់ពិន័យអន្តរការណ៍ជូនភ្នាក់ងារ អធិការកិច្ចពូជដំណាំមានសមត្ថកិច្ចដឹកនាំបេសកកម្មដោយផ្ទាល់ នៅកន្លែងកើតហេតុ ឬអាចប្រគល់ជូនអង្គភាព មានសមត្ថកិច្ចធ្វើអធិការកិច្ចពូជដំណាំសាមី នៅក្នុងរយៈពេលមិនលើសពី ៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃបាន ត្រួតពិនិត្យបទល្មើស និងបានចុះក្នុងកំណត់ហេតុត្រួតពិនិត្យ។

**ប្រការ ១១.-**

នៅក្នុងរយៈពេលមិនលើសពី ៥(ប្រាំ)ថ្ងៃ ក្រោយពេលបញ្ចប់បេសកកម្មអធិការកិច្ចពូជដំណាំភ្នាក់ងារ អធិការកិច្ចពូជដំណាំមានសមត្ថកិច្ចដឹកនាំបេសកកម្ម ត្រូវធ្វើរបាយការណ៍ជូនប្រធានអង្គភាពសាមី អំពីករណី បទល្មើសដែលជួបប្រទះ ដោយភ្ជាប់ជាមួយនូវកំណត់ហេតុត្រួតពិនិត្យ និងសំណុំបែបបទពាក់ព័ន្ធ។

ក្នុងករណីជនប្រព្រឹត្តល្មើសសារភាពកំហុស និងយល់ព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ភ្នាក់ងារអធិការកិច្ច ពូជដំណាំមានសមត្ថកិច្ចដឹកនាំបេសកកម្ម ត្រូវភ្ជាប់ជាមួយរបាយការណ៍នូវលិខិតសារភាពកំហុស និងយល់ព្រមបង់ ប្រាក់ពិន័យអន្តរការណ៍ ដើម្បីស្នើសុំប្រធានអង្គភាពមានសមត្ថកិច្ចសាមី ចេញសេចក្ដីសម្រេចពិន័យអន្តរការណ៍។

ក្នុងករណីជនប្រព្រឹត្តល្មើសមិនសារភាពកំហុស និងមិនយល់ព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ភ្នាក់ងារ អធិការកិច្ចពូជដំណាំមានសមត្ថកិច្ចដឹកនាំបេសកកម្ម ត្រូវលើកសំណើក្នុងរបាយការណ៍ជូនប្រធានអង្គភាពមាន សមត្ថកិច្ចសាមី ដើម្បីចេញលិខិតអញ្ជើញជនប្រព្រឹត្តល្មើសនោះ ឱ្យចូលខ្លួនមកដោះស្រាយករណីបទល្មើស នៅ អង្គភាពមានសមត្ថកិច្ចសាមី។

ក្នុងករណីជនប្រព្រឹត្តល្មើសមិនបានចូលមកដោះស្រាយបទល្មើស តាមរយៈលិខិតអញ្ជើញរបស់អង្គភាព មានសមត្ថកិច្ចសាមី ភ្នាក់ងារអធិការកិច្ចពូជដំណាំមានសមត្ថកិច្ចដឹកនាំបេសកកម្ម ត្រូវធ្វើរបាយការណ៍ជូន ប្រធានអង្គភាពមានសមត្ថកិច្ចសាមី ដោយភ្ជាប់ជាមួយសំណុំរឿងនៃបទល្មើសដែលត្រូវចងក្រង ដើម្បីបញ្ជូនទៅ តុលាការតាមនីតិវិធី។

៤/៧

**ប្រការ ១២.-**

នៅក្នុងប្រតិបត្តិការអធិការកិច្ចពូជដំណាំ ក្នុងករណីជួបប្រទះវត្ថុតាងពូជដំណាំល្មើសដែលបោះបង់ចោល ឬក្នុងករណីមិនស្គាល់អត្តសញ្ញាណជនប្រព្រឹត្តល្មើស ភ្នាក់ងារអធិការកិច្ចពូជដំណាំមានសមត្ថកិច្ចដឹកនាំបេសកកម្ម មានសិទ្ធិចាត់វិធានការឃាត់ទុកវត្ថុតាងនោះជាបណ្តោះអាសន្ន បំពេញកំណត់ហេតុត្រួតពិនិត្យ និងសំណុំបែបបទពាក់ព័ន្ធ ហើយត្រូវធ្វើរបាយការណ៍ជូនប្រធានអង្គភាពមានសមត្ថកិច្ចសាមី ដើម្បីចេញសេចក្តីជូនដំណឹងស្វែងរកជនប្រព្រឹត្តល្មើស ដែលពាក់ព័ន្ធនឹងវត្ថុតាងពូជដំណាំល្មើសនោះ ឱ្យចូលខ្លួនមកដោះស្រាយបទល្មើស នៅអង្គភាពមានសមត្ថកិច្ចសាមី។

ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ ដោយគិតចាប់ពីកាលបរិច្ឆេទចេញសេចក្តីជូនដំណឹង ក្នុងករណីគ្មានជនណាម្នាក់ចូលខ្លួនមកអះអាង និងទទួលស្គាល់លើវត្ថុតាងពូជដំណាំនោះទេ ភ្នាក់ងារអធិការកិច្ចពូជដំណាំមានសមត្ថកិច្ចដឹកនាំបេសកកម្ម ត្រូវធ្វើរបាយការណ៍ជូនប្រធានអង្គភាពមានសមត្ថកិច្ចសាមី ដោយភ្ជាប់ជាមួយសំណុំរឿងនៃបទល្មើសដែលត្រូវចងក្រង ដើម្បីបញ្ជូនទៅតុលាការតាមនីតិវិធី។

ក្នុងករណីមានជនណាចូលខ្លួនមកអះអាង និងទទួលស្គាល់លើវត្ថុតាងពូជដំណាំល្មើសនោះ ត្រូវឱ្យជននោះបង្ហាញឯកសារពាក់ព័ន្ធ ដែលបញ្ជាក់លើការទទួលខុសត្រូវជាម្ចាស់វត្ថុតាងពូជដំណាំល្មើសនោះ។ ករណីនេះភ្នាក់ងារអធិការកិច្ចពូជដំណាំមានសមត្ថកិច្ចដឹកនាំបេសកកម្ម ត្រូវដោះស្រាយករណីបទល្មើសដោយបំពេញសំណុំបែបបទពាក់ព័ន្ធ និងលើកសំណើក្នុងរបាយការណ៍ជូនប្រធានអង្គភាពមានសមត្ថកិច្ចសាមី ដើម្បីសម្រេចចាត់វិធានការតាមរយៈការពិន័យអន្តរការណ៍ ឬតាមនីតិវិធីផ្សេងទៀត ដោយអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ។

**ប្រការ ១៣.-**

ជនប្រព្រឹត្តល្មើសត្រូវបង់ប្រាក់ពិន័យអន្តរការណ៍នៅអង្គភាពមានសមត្ថកិច្ចសាមី ឬអាចបង់ប្រាក់ពិន័យអន្តរការណ៍នៅធនាគារជាតិ ឬនៅធនាគាររាជធានី ខេត្តសាមី នូវបរិមាណទឹកប្រាក់ដូចបានកំណត់ក្នុងសេចក្តីសម្រេចពិន័យអន្តរការណ៍នៅក្នុងរយៈពេលមិនលើសពី១៥(ដប់ប្រាំ)ថ្ងៃ គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេចពិន័យអន្តរការណ៍។

ក្នុងរយៈពេល ៩០(កៅសិប)ថ្ងៃ ក្រោយកាលបរិច្ឆេទផុតកំណត់នៃសេចក្តីសម្រេចពិន័យអន្តរការណ៍ ក្នុងករណីជនប្រព្រឹត្តល្មើសនៅតែមិនទាន់បានបង់ប្រាក់ពិន័យអន្តរការណ៍ ឬមិនបានបង់គ្រប់ចំនួន អង្គភាពមានសមត្ថកិច្ចសាមី ត្រូវបញ្ជូនសំណុំរឿងករណីបទល្មើសនេះទៅតុលាការតាមនីតិវិធី។

**ប្រការ ១៤.-**

នៅពេលជនប្រព្រឹត្តល្មើសបានបង់ប្រាក់ពិន័យអន្តរការណ៍គ្រប់ចំនួន ករណីបទល្មើសត្រូវបានរំលត់បណ្តឹងអាជ្ញា សាមីជនត្រូវរួចផុតពីការចោទប្រកាន់ទៅតុលាការ វត្ថុតាងនៃបទល្មើសត្រូវប្រគល់ជូនសាមីជនវិញ។ គ្រឹះស្ថានអាជីវកម្មពូជដំណាំ និងមធ្យោបាយពាក់ព័ន្ធបទល្មើសដែលបានផ្អាកសកម្មភាពជាបណ្តោះអាសន្ន ដោយភ្នាក់ងារអធិការកិច្ចពូជដំណាំ នៅក្នុងដំណើការអធិការកិច្ច និងដោះស្រាយបទល្មើស ត្រូវបានអនុញ្ញាតឱ្យដំណើការឡើងវិញ។ លិខិតអនុញ្ញាត ឬវិញ្ញាបនបត្រពាក់ព័ន្ធការធ្វើអាជីវកម្មពូជដំណាំ ដែលបានដកហូតជាបណ្តោះអាសន្ន ដោយភ្នាក់ងារអធិការកិច្ចពូជដំណាំ នៅក្នុងដំណើការអធិការកិច្ច និងដោះស្រាយបទល្មើស ត្រូវបានប្រគល់ឱ្យសាមីជនវិញ។

ភ្នាក់ងារអធិការកិច្ចពូជដំណាំមានសមត្ថកិច្ច ត្រូវបំពេញកំណត់ហេតុប្រគល់វត្ថុតាងពូជដំណាំជូនសាមីជនវិញ ដោយភ្ជាប់ជាមួយនូវសេចក្តីសម្រេចពិន័យអន្តរការណ៍ និងប័ណ្ណចំណូលបញ្ជាក់ការបង់ប្រាក់ពិន័យអន្តរការណ៍គ្រប់ចំនួន លើកលែងតែវត្ថុតាងដែលមានហានិភ័យខ្ពស់។

៥/៧

**ប្រការ ១៥.–**

ក្នុងករណីជនប្រព្រឹត្តល្មើសមិនរាងចាល ឬនៅតែបន្តប្រព្រឹត្តបទល្មើសដដែលថែមទៀត ត្រូវពិន័យអន្តរការណ៍ទ្វេដង និងត្រូវដកហូតលិខិតអនុញ្ញាតធ្វើអាជីវកម្ម លិខិតអនុញ្ញាតនាំចេញ នាំចូល វិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ ឬត្រូវបញ្ជូនសំណុំរឿងទៅតុលាការតាមនីតិវិធី។

**ប្រការ ១៦.–**

ការចំណាយលើសំណាកគំរូពូជដំណាំ ការពិសោធន៍បញ្ជាក់គុណភាព ការលើកដាក់ ការដឹកជញ្ជូន និងការថែរក្សាវត្ថុតាង នៅក្នុងដំណើរកោរអនុវត្តពិន័យអន្តរការណ៍ ជាបន្ទុករបស់ម្ចាស់វត្ថុតាង លើកលែងតែករណីវត្ថុតាងមិនស្គាល់អត្តសញ្ញាណម្ចាស់ ដែលរាល់ការចំណាយជាបន្ទុករបស់រដ្ឋ។

**ប្រការ ១៧.–**

ប្រធានអង្គភាពមានសមត្ថកិច្ចសាមី ត្រូវចុះក្នុងរបាយការណ៍របស់អង្គភាពជាប្រចាំ នូវរាល់ករណីពិន័យអន្តរការណ៍ ដែលអង្គភាពបានអនុវត្ត និងប្រាក់ពិន័យអន្តរការណ៍ដែលបានប្រមូល ដើម្បីរាយការណ៍ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ ១៨.–**

សំណុំបែបបទសម្រាប់ភ្នាក់ងារអធិការកិច្ចពូជដំណាំប្រើក្នុងការធ្វើអធិការកិច្ច និងពិន័យអន្តរការណ៍លើបទល្មើសអាជីវកម្មពូជដំណាំ មានដូចខាងក្រោម៖

- បែបបទ០១៖ កំណត់ហេតុត្រួតពិនិត្យ
- បែបបទ០២៖ កំណត់ហេតុឃាត់ទុកវត្ថុតាង
- បែបបទ០៣៖ កំណត់ហេតុដកយកគំរូសំណាក
- បែបបទ០៤៖ កំណត់ហេតុប្រគល់ ទទួល និងថែរក្សាវត្ថុតាង
- បែបបទ០៥៖ (ក) លិខិតអញ្ជើញ និង(ខ) លិខិតជូនដំណឹង
- បែបបទ០៦៖ លិខិតសារភាពកំហុស និងយល់ព្រមបង់ប្រាក់ពិន័យអន្តរការណ៍
- បែបបទ០៧៖ សេចក្តីសម្រេចស្តីពីការពិន័យអន្តរការណ៍
- បែបបទ០៨៖ កំណត់ហេតុប្រគល់វត្ថុតាងវិញ។

គំរូសំណុំបែបបទសម្រាប់ការពិន័យអន្តរការណ៍នៅក្នុងអធិការកិច្ចពូជដំណាំ ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ។

## ជំពូកទី៤
## តម្លៃទីផ្សារពូជដំណាំជាមូលដ្ឋានសម្រាប់អនុវត្តការពិន័យអន្តរការណ៍

**ប្រការ១៩.–**

ក្នុងករណីបទល្មើសអាជីវកម្មពូជដំណាំ ត្រូវពិន័យអន្តរការណ៍ដោយផ្អែកតាមតម្លៃវត្ថុតាងពិតប្រាកដលើទីផ្សារ អង្គភាពមានសមត្ថកិច្ចធ្វើអធិការកិច្ចពូជដំណាំសាមី ត្រូវចេញសេចក្តីសម្រេចពិន័យអន្តរការណ៍ ដោយផ្អែកតាមបញ្ជីតម្លៃទីផ្សារពូជដំណាំជាមូលដ្ឋានសម្រាប់អនុវត្តការពិន័យអន្តរការណ៍។

៦/៧៩ [signature]

**ប្រការ២០.-**

ក្នុងករណីបទល្មើសអាជីវកម្មពូជដំណាំដែលត្រូវនាំចេញ ឬនាំចូល តម្លៃទីផ្សារជាមូលដ្ឋានសម្រាប់អនុវត្តការពិន័យអន្តរការណ៍ ត្រូវផ្អែកតាមវិក្កយបត្រចេញដោយប្រទេសប្រភពដើមនៃពូជដំណាំនោះ ដែលប្រើសម្រាប់ធ្វើប្រតិវេទន៍គយ។

ក្នុងករណីគ្មានវិក្កយបត្រប្រភពដើមច្បាស់លាស់ ការពិន័យអន្តរការណ៍លើពូជដំណាំល្មើសដែលត្រូវនាំចេញ ឬនាំចូលនោះ ត្រូវផ្អែកតាមបញ្ជីតម្លៃទីផ្សារពូជដំណាំជាមូលដ្ឋានសម្រាប់អនុវត្តការពិន័យអន្តរការណ៍។

**ប្រការ២១.-**

បញ្ជីតម្លៃទីផ្សារពូជដំណាំជាមូលដ្ឋានសម្រាប់អនុវត្តការពិន័យអន្តរការណ៍ លើបទល្មើសអាជីវកម្មពូជដំណាំ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

បញ្ជីតម្លៃទីផ្សារពូជដំណាំជាមូលដ្ឋានសម្រាប់អនុវត្តការពិន័យអន្តរការណ៍ អាចកែប្រែឡើងវិញតាមរយៈប្រកាសស្តីពីការកែប្រែឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**ប្រការ ២២.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ ២៣.-**

អគ្គលេខាធិការ អគ្គាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងខ្លួនៗ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១១ កើត ខែបឋមាសាឍ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ២៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី១នៃប្រកាសលេខ.២៣២......ប្រក.កសក ចុះថ្ងៃទី.០៥.....ខែ.កក្កដា....ឆ្នាំ..២០២១..
"ស្ដីពីបែបបទនៃការពិន័យអន្តរការណ៍ និងតម្លៃទីផ្សារពូជដំណាំជាមូលដ្ឋានសម្រាប់អនុវត្តការពិន័យអន្តរការណ៍"

## គំរូសំណុំបែបបទសម្រាប់ការពិន័យអន្តរការណ៍នៅក្នុងអធិការកិច្ចពូជដំណាំ

| លេខទម្រង់ | ឈ្មោះគំរូសំណុំបែបបទ | ចំនួនទំព័រ |
|---|---|---|
| ០១ | ទម្រង់កំណត់ហេតុត្រួតពិនិត្យ | ៧ |
| ០២ | កំណត់ហេតុឃាត់ទុកវត្ថុតាង | ៣ |
| ០៣ | កំណត់ហេតុដកយកគំរូសំណាក | ៣ |
| ០៤ | កំណត់ហេតុប្រគល់ ទទួល និងថែរក្សាវត្ថុតាង | ៣ |
| ០៥ | - (ក) លិខិតអញ្ជើញ | ១ |
| | - (ខ) លិខិតជូនដំណឹង | ១ |
| ០៦ | លិខិតសារភាពកំហុស និងយល់ព្រមបង់ប្រាក់ពិន័យអន្តរការណ៍ | ១ |
| ០៧ | សេចក្ដីសម្រេចស្ដីពីការពិន័យអន្តរកាណ៍ | ២ |
| ០៨ | កំណត់ហេតុប្រគល់វត្ថុតាងវិញ | ៣ |

ម៉ែបបទ០១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
(១) ..............................................................

## កំណត់ហេតុត្រួតពិនិត្យ

ឆ្នាំពីរពាន់.............. ខែ..................... ថ្ងៃទី ................. វេលាម៉ោង...............................

យើង............................................ឋានៈ............................................................

ជាភ្នាក់ងារអធិការកិច្ចពូជដំណាំ ដែលមាននីតិសម្បទាជានគរបាលយុត្តិធម៌នៃអង្គភាព(២).............
......................................................................................................................................

តាមលិខិតបញ្ជាបេសកកម្មលេខ ............................ ចុះថ្ងៃទី........... ខែ............. ឆ្នាំ២០.........

ចេញដោយ ...................................................................................................................។

យើងបានដឹកនាំបេសកកម្មធ្វើអធិការកិច្ចពូជដំណាំ ប្រកបដោយឯកសណ្ឋានត្រឹមត្រូវ និងអម ដោយមន្ត្រីជំនួយការៈ

១- លោក..................................... ឋានៈ ..................................................................

២- លោក..................................... ឋានៈ ..................................................................

៣- លោក..................................... ឋានៈ ..................................................................

ដោយមានការចូលរួមសហការពីមន្ត្រីមានសមត្ថកិច្ច និងអ្នកបកប្រែភាសា(បើសិនជាមាន)៖

១- លោក..................................... ឋានៈ ..................................................................

២- លោក..................................... ឋានៈ ..................................................................

៣- លោក..................................... ឋានៈ ..................................................................

៤- លោក..................................... មុខងារជាអ្នកបកប្រែភាសា។

យើងបានចុះធ្វើប្រតិបត្តិការត្រួតពិនិត្យផ្ទាល់នៅកន្លែងកើតហេតុ ដោយបានជួបហេតុការណ៍ និងបានកត់ត្រា ដូចខាងក្រោម៖

**១- កន្លែងកើតហេតុ**

☐គ្រឹះស្ថានអាជីវកម្ម ☐កសិដ្ឋាន

☐មធ្យោបាយដឹកជញ្ជូន ...............................................................................................

☐កន្លែងកើតហេតុផ្សេងទៀត៖.........................................................................................

មានទីតាំងនៅត្រង់ចំណុច...............................................................................................

---

[១] អគ្គនាយកដ្ឋានកសិកម្ម ឬមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត។

[២] នាយកដ្ឋានពូជដំណាំនៃអគ្គនាយកដ្ឋានកសិកម្ម ឬមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត។

បែបបទ០១

ភូមិ................................................................ឃុំ/សង្កាត់.......................................................

ក្រុង/ស្រុក/ខណ្ឌ ..............................................រាជធានី/ខេត្ត..................................................។

**២- សមាសភាពនៅពេលត្រួតពិនិត្យ**

យើងបានធ្វើការត្រួតពិនិត្យនៅចំពោះមុខមន្ត្រីចូលរួមទាំងអស់ និងជនសង្ស័យដែលទទួលខុសត្រូវលើទីតាំងកន្លែងកើតហេតុ ដែលមាន៖

ឈ្មោះ ..........................................ឈ្មោះហៅក្រៅ...............................................ភេទ ...........

ថ្ងៃខែឆ្នាំកំណើត ...........................ជនជាតិ...................សញ្ជាតិ............................................

ទីកន្លែងកំណើត..................................................................................................................

ទីលំនៅបច្ចុប្បន្ន..................................................................................................................

មុខរបរ..............................................................................................................................

អត្តសញ្ញាណប័ណ្ណលេខ ...................... ចុះថ្ងៃទី ...................... ផុតកំណត់ថ្ងៃទី ......................

លិខិតឆ្លងដែនលេខ ............................ ចុះថ្ងៃទី ...................... ផុតកំណត់ថ្ងៃទី ......................

ជនសង្ស័យផ្សេងទៀត ត្រូវបានកត់ត្រាចូលក្នុងព្រឹត្តិប័ត្រជនសង្ស័យ ភ្ជាប់ជាមួយកំណត់ហេតុត្រួតពិនិត្យនេះ (ឯកសារភ្ជាប់០១-១)។

**ដោយមានសាក្សីចូលរួម** (បើសិនជាមាន)៖

១- ឈ្មោះ ...................................ឈ្មោះហៅក្រៅ...............................................ភេទ ...........

ថ្ងៃខែឆ្នាំកំណើត ...........................ជនជាតិ...................សញ្ជាតិ............................................

ទីកន្លែងកំណើត..................................................................................................................

ទីលំនៅបច្ចុប្បន្ន..................................................................................................................

មុខរបរ..............................................................................................................................

អត្តសញ្ញាណប័ណ្ណលេខ ...................... ចុះថ្ងៃទី ...................... ផុតកំណត់ថ្ងៃទី ......................

លិខិតឆ្លងដែនលេខ ............................ ចុះថ្ងៃទី ...................... ផុតកំណត់ថ្ងៃទី ......................

២- ឈ្មោះ...................................ឈ្មោះហៅក្រៅ...............................................ភេទ ...........

ថ្ងៃខែឆ្នាំកំណើត ...........................ជនជាតិ...................សញ្ជាតិ............................................

ទីកន្លែងកំណើត..................................................................................................................

ទីលំនៅបច្ចុប្បន្ន..................................................................................................................

មុខរបរ..............................................................................................................................

អត្តសញ្ញាណប័ណ្ណលេខ ...................... ចុះថ្ងៃទី ...................... ផុតកំណត់ថ្ងៃទី ......................

លិខិតឆ្លងដែនលេខ ............................ ចុះថ្ងៃទី ...................... ផុតកំណត់ថ្ងៃទី ......................

**៣- អង្គហេតុ**

នៅក្នុងពេលធ្វើការត្រួតពិនិត្យជាក់ស្តែងនៅកន្លែងកើតហេតុ បានបញ្ជាក់នូវសកម្មភាពល្មើសច្បាប់ដូចខាងក្រោម[៣]៖

---

[៣] រៀបរាប់អំពីស្ថានភាព ឬសកម្មភាពជាក់ស្តែង ស្លាកស្នាម វត្ថុតាង ដែលបានឃើញនៅកន្លែងកើតហេតុ ឬភស្តុតាងផ្សេងទៀតដែល បញ្ជាក់ថាជាបទល្មើសជាក់ស្តែង។

២/៧

បែបបទ០១

..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................

**៤- វត្ថុតាង**

យើងបានប្រទះឃើញវត្ថុតាង ដែលបានបន្សល់ទុកនៅកន្លែងកើតហេតុ[៨] ដូចខាងក្រោម៖

..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................
..........................................................................................................................................................

---

[៨] កត់ត្រានូវវត្ថុតាងពិតប្រាកដជាពូជដំណាំ ចំនួនប្រភេទ និងបរិមាណសរុប ព្រមទាំងវត្ថុតាងផ្សេងទៀតដែលប្រើប្រាស់ជា មធ្យោបាយប្រព្រឹត្តបទល្មើស។ បញ្ជីលម្អិតនៃវត្ថុតាងត្រូវកត់ត្រាដោយឡែកនៅក្នុងកំណត់ហេតុឃាត់ទុកវត្ថុតាង។

បែបបទ០១

..............................................................................................................................
..............................................................................................................................
..............................................................................................................................
..............................................................................................................................
..............................................................................................................................
..............................................................................................................................
..............................................................................................................................
..............................................................................................................................
..............................................................................................................................
..............................................................................................................................
..............................................................................................................................
..............................................................................................................................
..............................................................................................................................

**៥- សម្រង់ព័ត៌មាន**

នៅចំពោះមុខមន្ត្រីចូលរួមទាំងអស់ យើងបានសួរព័ត៌មានពាក់ព័ន្ធបទល្មើស ដូចខាងក្រោម៖

..............................................................................................................................
..............................................................................................................................
..............................................................................................................................
..............................................................................................................................
..............................................................................................................................
..............................................................................................................................
..............................................................................................................................
..............................................................................................................................
..............................................................................................................................
..............................................................................................................................
..............................................................................................................................
..............................................................................................................................
..............................................................................................................................
..............................................................................................................................
..............................................................................................................................
..............................................................................................................................
..............................................................................................................................
..............................................................................................................................
..............................................................................................................................
..............................................................................................................................

បែបបទ០១

**៦- វិធានការនៅកន្លែងកើតហេតុ**

នៅចំពោះមុខមន្ត្រីចូលរួម និងជនសង្ស័យដែលទទួលខុសត្រូវលើករណីបទល្មើសនេះយើងបានចាត់វិធានការបណ្ដោះអាសន្ននៅនឹងកន្លែងកើតហេតុ ដូចខាងក្រោម៖

☐ ឃាត់ទុកជាបណ្ដោះអាសន្ននិងបិទស្លាកសម្គាល់វត្ថុតាងដោយធ្វើកំណត់ហេតុឃាត់ទុកវត្ថុតាង។

☐ ផ្អាកជាបណ្ដោះអាសន្នចំពោះសកម្មភាពល្មើសច្បាប់របស់៖

- ○ គ្រឹះស្ថានអាជីវកម្មពូជដំណាំ
- ○ មធ្យោបាយដឹកជញ្ជូន ឬផ្ទុកពូជដំណាំ
- ○ ទីតាំង ឬមធ្យោបាយផ្សេងទៀតដែលពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើស។

☐ ដកហូតជាបណ្ដោះអាសន្ននូវវិញ្ញាបនបត្រ និងលិខិតអនុញ្ញាតពាក់ព័ន្ធការធ្វើអាជីវកម្មពូជដំណាំ ដូចខាងក្រោម៖.............................................................................................

.............................................................................................................................

.............................................................................................................................

.............................................................................................................................

.............................................................................................................................

.............................................................................................................................។

☐ ដកយកគំរូសំណាកពូជដំណាំដែលបានត្រួតពិនិត្យ ដើម្បីធ្វើពិសោធន៍ផ្ទៀងផ្ទាត់អនុលោមភាពគុណភាពពូជដំណាំ ដោយធ្វើកំណត់ហេតុដកយកគំរូសំណាក។

☐ ធ្វើការប្រគល់ ទទួល និងថែរក្សាវត្ថុតាងនៅនឹងកន្លែងកើតហេតុ ដោយធ្វើកំណត់ហេតុប្រគល់ទទួល និងថែរក្សាវត្ថុតាង។

**៧- អនុច្ឆេទច្បាប់**

នៅចំពោះមុខមន្ត្រីចូលរួម និងជនសង្ស័យ យើងបានបញ្ជាក់ប្រាប់អំពីកំហុសដែលសាមីជន បានប្រព្រឹត្តល្មើសចំពោះច្បាប់ស្ដីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ និងទណ្ឌកម្មដែលសាមីជនត្រូវទទួល ព្រមទាំងនីតិវិធីត្រូវដោះស្រាយ លើករណីល្មើសច្បាប់នេះ ដូចខាងក្រោម៖

(១) សាមីជនបានប្រព្រឹត្តល្មើសនឹងមាត្រា.......................................................ពីបទ៖

.............................................................................................................................

.............................................................................................................................

.............................................................................................................................

(២) សាមីជនត្រូវទទួលទណ្ឌកម្ម តាមមាត្រា ..............................................................

នៃច្បាប់ស្ដីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជអ្នកដំណាំ ដែលត្រូវ៖

☐ ពិន័យអន្តរការណ៍។

☐ ដកហូតលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រពាក់ព័ន្ធ។

☐ ទទួលទណ្ឌកម្មដោយតុលាការ។

៥/៧

បែបបទ០១

ការត្រួតពិនិត្យនេះពុំបណ្តាលឱ្យមានការខូចខាត ឬបាត់បង់ទ្រព្យសម្បត្តិរបស់អ្នកកាន់កាប់កន្លែងកើតហេតុឡើយ។

- ☐ យើងបានថតរូបភាពនៅកន្លែងកើតហេតុ និងប្រមូលឯកសារផ្សេងទៀតដើម្បីទុកជាកស្តុតាងសម្រាប់ករណីបទល្មើសនេះ។
- ☐ យើងបានធ្វើកំណត់ហេតុឃាត់ទុកវត្ថុតាង។
- ☐ យើងបានធ្វើកំណត់ហេតុប្រគល់ ទទួល និងថែរក្សាវត្ថុតាង។
- ☐ យើងបានបំពេញបែបបទផ្សេងទៀត ដូចមានភ្ជាប់ជាមួយ។

កំណត់ហេតុនេះ បានបញ្ចប់នៅកន្លែងកើតហេតុ នៅវេលាម៉ោង..............................នាថ្ងៃ ខែ ឆ្នាំដដែល។

កំណត់ហេតុនេះ នឹងត្រូវបញ្ជូនទៅ[៥]........................................................................ ដើម្បីពិនិត្យសម្រេចតាមនីតិវិធី។

